ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...០៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការពង្រឹង និងពង្រីកការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១.-**

បង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលហៅកាត់ថា "គ.ជ.ប.ប" ដើម្បីសម្របសម្រួលជាមួយក្រសួង ស្ថាប័នអង្គការនានាដែលពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អោយឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន និងទៅអនាគតនៅកម្ពុជា។

**មាត្រា ២.-**

- សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាលមានដូចខាងក្រោម :

| | |
|---|---|
| ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |

| | |
|---|---|
| ៤. តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥. តំណាងនិយោជក | អនុប្រធាន |
| ៦. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧. តំណាងក្រសួងពាណិជ្ជកម្ម | - |
| ៨. តំណាងក្រសួងសុខាភិបាល | - |
| ៩. តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | - |
| ១០. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | - |
| ១១. តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - |
| ១២. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | - |
| ១៣. តំណាងក្រសួងទេសចរណ៍ | - |
| ១៤. តំណាងក្រសួងកិច្ចការនារី | - |
| ១៥. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | - |
| ១៦. តំណាងក្រសួងធនធានទឹក និងឧតុនិយម | - |
| ១៧. តំណាងក្រសួងផែនការ | - |
| ១៨. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - |
| ១៩. តំណាងក្រសួងបរិស្ថាន | - |
| ២០. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | - |
| ២១. តំណាង ៤រូប របស់និយោជក | - |
| ២២. តំណាង ១រូប របស់សភាពាណិជ្ជកម្ម | - |
| ២៣. តំណាង ២រូប របស់និយោជិក | - |
| ២៤. តំណាង ៣រូប ជាអ្នកផ្តល់ការបណ្តុះបណ្តាល | - |
| ២៥. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | នាយកប្រតិបត្តិ |

- គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមបាន។
- គណៈកម្មាធិការជាតិនេះមាន អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។

មាត្រា ៣.-

គណៈកម្មាធិការជាតិនេះមានភារកិច្ច :

- រៀបចំគោលនយោបាយ និងគំរោងផែនការជាតិ សំរាប់អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។
- សម្របសម្រួល និងតំរង់ទិសការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

- លើកកំពស់កែទម្រង់ និងអភិវឌ្ឍប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអោយក្លាយជាប្រព័ន្ធមួយដែល :
    - មានគុណភាព និងប្រសិទ្ធភាពខ្ពស់
    - ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍន៍ជាតិ
    - ឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ។ល។
    - មានទំនាក់ទំនងរវាងកន្លែងធ្វើការងារ និងគ្រឹះស្ថានបណ្តុះបណ្តាល

## មាត្រា ៤.-

- គណៈកម្មាធិការជាតិ ត្រូវជ្រើសតាំងសមាជិករបស់ខ្លួន ៩រូប ធ្វើជាគណៈកម្មការប្រតិបត្តិ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| - តំណាង ២រូប របស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល | សមាជិក |
| - តំណាង ២រូប របស់និយោជក | - |
| - តំណាង ១រូប របស់និយោជិក | - |
| - តំណាង ១រូប របស់អ្នកផ្តល់ការបណ្តុះបណ្តាល | - |

- គណៈកម្មការប្រតិបត្តិអាចអញ្ជើញតំណាង ១រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចូលរួម ។
- គណៈកម្មការប្រតិបត្តិនេះមាននាយកប្រតិបត្តិធ្វើជាលេខាអចិន្ត្រៃយ៍ ។

## មាត្រា ៥.-

គណៈកម្មការប្រតិបត្តិនេះមានភារកិច្ច :

- គ្រប់គ្រងក្នុងនាមគណៈកម្មាធិការជាតិ នូវមូលនិធិជាតិបណ្តុះបណ្តាល ។
- រៀបចំកម្មវិធី និងរបៀបវារៈប្រជុំ របស់គណៈកម្មាធិការជាតិ ។
- លើកសំណើដែលពាក់ព័ន្ធដល់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជូនគណៈកម្មាធិការជាតិពិនិត្យ និងសំរេច ។

## មាត្រា ៦.-

នៅតាមខេត្ត-ក្រុង ត្រូវបង្កើតអោយមានគណៈកម្មាធិការសម្របសម្រួលការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈថ្នាក់ខេត្ត-ក្រុង ដែលហៅកាត់ថា គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ។ សមាសភាពគណៈកម្មាធិការនេះរួមមាន : អភិបាលខេត្ត-ក្រុងជាប្រធាន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាអនុប្រធាន ប្រធានមន្ទីរពាក់ព័ន្ធ តំណាងអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិក និងតំណាងអ្នកផ្តល់ការបណ្តុះបណ្តាលជាសមាជិក ហើយមានការិយាល័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង ជាលេខាធិការដ្ឋាន ។

មាត្រា ៧.-

ភារកិច្ចរបស់គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ត្រូវកំណត់ក្នុងលក្ខន្តិកៈដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល ។

មាត្រា ៨.-

គណៈកម្មាធិការជាតិបណ្តុះបណ្តាលមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិបណ្តុះបណ្តាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩៧ ខែ៩៨ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១០
- ឯកសារ-កាលប្បវត្តិ